ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៩៩..០២.១៦..៥០.០២..ធ.ក..ស.ល

# សេចក្តីជូនដំណឹង
# ស្តីពី
# វិធីសាស្ត្រកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជា មានតួនាទីរៀបចំ និងកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅរៀងរាល់ថ្ងៃធ្វើការ និងដាក់ផ្សព្វផ្សាយនៅម៉ោង ៩:៣០ នាទីរសៀល លើប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ប្រសិទ្ធភាពប្រើប្រាស់នៅថ្ងៃធ្វើការបន្ទាប់។ ដើម្បីធានាថាអត្រាប្តូរប្រាក់ផ្លូវការមានភាពច្បាស់លាស់ តម្លាភាព សុក្រិតភាព និងឆ្លុះបញ្ចាំងពីអត្រាប្តូរប្រាក់នៅលើទីផ្សារ អត្រាប្តូរប្រាក់ផ្លូវការត្រូវបានគណនាដោយផ្អែកតាមវិធីសាស្ត្រចំនួន៣ដូចខាងក្រោម៖

**១. ករណីប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារធម្មតា:** ប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារតាមរយៈប្រព័ន្ធ NBCP FX Platform មានទំហំទឹកប្រាក់ស្មើឬលើស ៥លានដុល្លារអាមេរិក និងមានគ្រឹះស្ថានធនាគារចូលរួមចាប់ពី ៣គ្រឹះស្ថាន៖ ***អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាផ្អែកលើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរ (The Volume Weighted Average Exchange Rate) ក្នុងទីផ្សារអន្តរធនាគារដែលបានបញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform (ក)។***

**២. ករណីប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារមានកម្រិត:** ប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារតាមរយៈប្រព័ន្ធ NBCP FX Platform មានទំហំទឹកប្រាក់តិចជាង ៥លានដុល្លារអាមេរិក និង/ឬចំនួនគ្រឹះស្ថានធនាគារចូលរួមតិចជាង ៣គ្រឹះស្ថាន៖ ***អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាផ្អែកលើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរក្នុងទីផ្សារអន្តរធនាគារដែលបានបញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform (ក) និងអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាងគ្រឹះស្ថានធនាគារ និងអតិថិជនដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ (ខ)*។***

**រូបមន្តគណនា៖**

អត្រាប្តូរប្រាក់ផ្លូវការ = (០,៥ x "ក") + (០,៥ x "ខ")

---

* **Outlier Rule;** វិធាននេះត្រូវបានអនុវត្តក្នុងគោលបំណងធានាថា រាល់អត្រាប្តូរប្រាក់របស់ប្រតិបត្តិការទិញ-លក់ដែលមិនមានភាពប្រក្រតី និងខុសពីស្ថានភាពជាក់ស្តែងនៃទីផ្សារប្តូរប្រាក់ ត្រូវបានដកចេញពីការគណនាអត្រាប្តូរប្រាក់ផ្លូវការ។ ការគណនាអត្រាប្តូរប្រាក់ផ្លូវការ (OER) នឹងដកចេញនូវប្រតិបត្តិការដែលមានអត្រាប្តូរប្រាក់ដែលមានកម្រិតខ្ពស់បំផុត និងទាបបំផុតចំនួន ១ ភាគរយ (1% Percentile)



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- **"ក"** អត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរក្នុងទីផ្សារអន្តរធនាគារដែលបានបញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform

- **"ខ"** អត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាងគ្រឹះស្ថានធនាគារ និងអតិថិជនដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ។

**៣. ករណីមិនមានប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារ:** ករណីមិនមានប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងប្រព័ន្ធ NBCP FX Platform៖ ***អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាងគ្រឹះស្ថានធនាគារ និងអតិថិជនដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ (ខ)*។***

*ថ្ងៃព្រហស្បតិ៍ ៧រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦*


**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៩០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_